**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No. 44 PR-23/EoJ 17 November 2023

## Japan Provides US$252,136 for Facility Improvement at Physical Rehabilitation Center, and Procurement of Medical Equipment at Children Hospital

The Government of Japan will provide US$252,136 in total for two recipient organizations under the framework, *the Grant Assistance for Grassroots Human Security Projects ("KUSANONE")*. The Grant Contracts were signed today between Mr. TANINAI Ichitomo, Minister / Deputy Chief of Mission, Embassy of Japan in the Kingdom of Cambodia, and the representatives of two recipients respectively, to carry out the following project.

1. 'The Project for Construction of Dormitory and Installment of Equipment at Prey Veng Physical Rehabilitation Center ' (US$128,301)
Recipient: Prey Veng Physical Rehabilitation Center
This grant will be used to install 13 kinds of prosthesis manufacturing and rehabilitation equipment and to construct a dormitory with kitchen for patients who visit Prey Veng Physical Rehabilitation Center (PRC) in Prey Veng Province. The PRC has been facing challenges such as the deterioration of necessary equipment to produce prosthesis and orthotics, and the lack of capacity of current dormitory and the bad access to the toilet and main building. Through this project, it is expected to benefit around 850 patients annually with the improved facility and services.

2. 'The Project for the Procurement of Medical Equipment at Angkor Hospital for Children in Siem Reap Province ' (US$123,835)
Recipient: Angkor Hospital for Children
This grant will be used to procure 4 kinds of medical equipment (1 operation table, 1 cardiac monitor, 1 anesthesia machine, 2 syringe pumps) to improve the quality of emergency care at Angkor Hospital for Children. It would enhance the efficiency and productivity of medical staffs who treat children with critical conditions. Through the improved medical services, it is expected to benefit around 6,300 children annually.

Japan's *"KUSANONE" Projects* started in Cambodia in 1991 in order to support Cambodia's reconstruction and development at the grassroots level. The assistance aims to protect those who are vulnerable due to various factors such as poverty and misfortunes that directly threaten their lives, livelihood, and dignity, as well as to promote self-reliance of local communities.

Since 1991, the Government of Japan has provided over US$69 million for mainly local authorities and non-governmental organizations to implement 687 *KUSANONE* projects throughout Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161*
*Email:* eco.jpn@pp.mofa.go.jp
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

លេខ. 44 PR-23/EoJ

ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣

## ជប៉ុនផ្តល់ថវិកា ២៥២,១៣៦ ដុល្លារអាមេរិក សម្រាប់ការកែលម្អបរិក្ខារនៅមជ្ឈមណ្ឌលស្តារលទ្ធភាព ពលកម្មកាយសម្បទា និងលទ្ធកម្មបរិក្ខារពេទ្យនៅមន្ទីរពេទ្យកុមារ

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **២៥២,១៣៦ ដុល្លារអាមេរិក** ដល់ស្ថាប័នទទួលជំនួយចំនួនពីរ ក្រោមគ្រោងការណ៍ ជំនួយឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ (គូសាណូណិ) ។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **លោក តានិណៃ អ៊ិឈិតុម៉ុ** ឧបទូតនៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងស្ថាប័នទទួលជំនួយទាំងពីរ ដើម្បីអនុវត្តគម្រោងខាងក្រោម៖

### ១. គម្រោងសាងសង់អគារស្នាក់នៅ និងដំឡើងឧបករណ៍នៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រៃវែង (ថវិកាចំនួន ១២៨,៣០១ ដុល្លារអាមេរិក)

ស្ថាប័នទទួលជំនួយ៖ មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រៃវែង

ជំនួយនេះនឹងត្រូវបានប្រើប្រាស់ដើម្បីដំឡើងឧបករណ៍ចំនួន១៣ប្រភេទ សម្រាប់ផលិតឧបករណ៍សិប្បនិម្មិត និងស្តារនីតិសម្បទា និងដើម្បីសាងសង់អគារស្នាក់នៅ រួមជាមួយផ្ទះបាយសម្រាប់អ្នកជំងឺដែលមកព្យាបាល នៅមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រៃវែង (PRC) ក្នុងខេត្តព្រៃវែង។ PRC នេះ បាននិងកំពុងជួបបញ្ហាប្រឈមដូចជាភាពសឹករិចរិលនៃឧបករណ៍ចាំបាច់ ដើម្បីផលិតឧបករណ៍សិប្បនិម្មិត និងរណប និងកង្វះសមត្ថភាពនៃអគារស្នាក់នៅបច្ចុប្បន្ន និងមានការលំបាកចំពោះផ្លូវទៅបង្គន់ និងអគារធំ។ តាមរយៈគម្រោងនេះ យើងរំពឹងថា អ្នកជំងឺប្រមាណ ៨៥០ នាក់ ជារៀងរាល់ឆ្នាំ នឹងទទួលបានអត្ថប្រយោជន៍ពីបរិក្ខារ និងសេវាកម្ម ដែលមានភាពប្រសើរជាងមុន។

**២. គម្រោងលទ្ធកម្មបរិក្ខារពេទ្យនៅមន្ទីរពេទ្យកុមារអង្គរ ក្នុងខេត្តសៀមរាប (ថវិកាចំនួន ១២៣,៨៣៥ ដុល្លារអាមេរិក)**

ស្ថាប័នទទួលជំនួយ៖ មន្ទីរពេទ្យកុមារអង្គរ

ជំនួយនេះនឹងត្រូវបានប្រើប្រាស់ដើម្បីទិញបរិក្ខារពេទ្យចំនួន ៤ ប្រភេទ (គ្រែវះកាត់ចំនួន១ ម៉ាស៊ីនតាមដានចង្វាក់បេះដូងចំនួន១ ម៉ាស៊ីនតាមដានអ្នកជំងឺដាក់ថ្នាំសណ្តំចំនួន១ សឺរ៉ាំងអេឡិចត្រូនិក ចំនួន២) ដើម្បីបង្កើនគុណភាពនៃការថែទាំសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យកុមារអង្គរ។ ឧបករណ៍ទាំងនេះនឹងពង្រឹងសក្តិសិទ្ធភាព និងផលិតភាពរបស់បុគ្គលិកពេទ្យ ដែលព្យាបាលកុមារដែលមានលក្ខខណ្ឌធ្ងន់ធ្ងរ។ តាមរយៈសេវាវេជ្ជសាស្ត្រដែលមានភាពប្រសើរជាងមុន យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍ដល់កុមារប្រមាណ ៦,៣០០ នាក់ ជារៀងរាល់ឆ្នាំ។

ជំនួយឥតសំណងគូសាណូណិរបស់ជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍ និងស្ថាបនាប្រទេសឡើងវិញ នៅកម្រិតមូលដ្ឋាន។ ជំនួយឥតសំណងនេះ មានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និង ភាពអកុសលនានា ដែលអាចគំរាមកំហែងដោយផ្ទាល់ដល់អាយុជីវិត ជីវភាពរស់នៅ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកា ជាង៦៩លានដុល្លារអាមេរិក ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តគម្រោងគូសាណូណិចំនួន ៦៨៧ គម្រោង នៅទូទាំងប្រទេសកម្ពុជា៕

---

*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០*
*អ៊ីម៉ែល៖ eco.jpn@pp.mofa.go.jp*
*គេហទំព័រ៖ http://www.kh.emb-japan.go.jp*

សុន្ទរកថារបស់ **លោក តានិណៃ អ៊ិឈិតុម៉ុ**
ឧបទូតនៃស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ
ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣

សូមគោរព
- **ឯកឧត្តម ខុម ផលលឿន** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជានាយកមូលនិធិជនពិការ (PWDF)
- **លោក ឃុត ឈុនលី** ប្រធានមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រៃវែង
- **លោកវេជ្ជបណ្ឌិត ងួន ច័ន្ទភក្ត្រា** នាយកមន្ទីរពេទ្យកុមារអង្គរ
- លោក លោកស្រី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយឥតសំណង សម្រាប់គម្រោងគូសាណូណិ ឬគម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ នាថ្ងៃនេះ។

ចាប់តាំងពីឆ្នាំ១៩៩១ បន្ថែមលើគម្រោងឥណទាននិងជំនួយឥតសំណងខ្នាតធំ រដ្ឋាភិបាលជប៉ុន បាននិងកំពុងអនុវត្តគម្រោងគូសាណូណិនៅកម្ពុជា ដើម្បីជួយដោយផ្ទាល់ដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលនានា ក្នុងការអនុវត្តគម្រោងរបស់ពួកគាត់។ គូសាណូណិ មានន័យថា "ឬសស្មៅ" ក្នុងភាសាជប៉ុន។ នៅក្នុងរយៈពេលជាង៣០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុន បានចូលរួមចំណែកក្នុងគម្រោងជាង ៦៨៧ នៅទូទាំងប្រទេសកម្ពុជា តាមរយៈគ្រោងការណ៍នេះ។ យើងមានសេចក្តីសោមនស្សរីករាយដែលគម្រោងទាំងនេះ បានចូលរួមចំណែកដោយផ្ទាល់ក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជានៅកម្រិតមូលដ្ឋាន។

ថ្ងៃនេះ ខ្ញុំសូមណែនាំគម្រោងចំនួនពីរដែលបានចុះហត្ថលេខា ដូចខាងក្រោម៖

សម្រាប់គម្រោងទី១ សម្រាប់មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាខេត្តព្រៃវែង រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១២៨,៣០១ ដុល្លារអាមេរិក (មួយរយម្ភៃប្រាំបីពាន់ បីរយមួយដុល្លាអាមេរិក) ដើម្បីដំឡើងឧបករណ៍ចំនួន១៣ប្រភេទ សម្រាប់ផលិតឧបករណ៍សិប្បនិម្មិត និងស្តារនីតិសម្បទា និងដើម្បីសាងសង់អគារស្នាក់នៅ រួមជាមួយផ្ទះបាយ។ បរិក្ខារទាំងនេះនឹងរួមចំណែកកែលម្អសេវាដែលផ្តល់នៅមជ្ឈមណ្ឌលស្តារនីតិសម្បទានេះ។

សម្រាប់គម្រោងទី២ សម្រាប់មន្ទីរពេទ្យកុមារអង្គរ រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ១២៣,៨៣៥ ដុល្លារអាមេរិក (មួយរយម្ភៃបីពាន់ប្រាំបីរយសាមសិបប្រាំដុល្លារអាមេរិក) ដើម្បីដំឡើងបរិក្ខារពេទ្យចំនួន ៤ ប្រភេទ ដែលមានសារៈសំខាន់សម្រាប់ដោះស្រាយករណីសង្គ្រោះបន្ទាន់។ យើងរំពឹងថាគម្រោងនេះនឹងផ្តល់អត្ថប្រយោជន៍

ដល់កុមារប្រមាណ ៦,៣០០ នាក់ ជារៀងរាល់ឆ្នាំ តាមរយៈការពង្រឹងសក្តិសិទ្ធភាព និងផលិតភាពរបស់បុគ្គលិកពេទ្យ។

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយសង្កេតឃើញការអភិវឌ្ឍយ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ទោះជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អគុណភាពជីវិត។ ជប៉ុននឹងបន្តចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ តាមរយៈគ្រោងការណ៍សហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ផ្សេងៗ រួមទាំងគូសាណូណិផងដែរ។

សូមអរគុណសម្រាប់ការចូលរួមក្នុងពិធីចុះហត្ថលេខានាថ្ងៃនេះ។ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមមានសុខភាពល្អ សុភមង្គល និង សូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

សូមអរគុណ៕